# កល្លាតិយជាតក

## (រឿងសេចក្តីស្នេហារបស់កិន្នរ)




*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមល្លិកាទេវី បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **កល្លាតិយោ ឆាម អហោសិ រាជ** *ដូច្នេះជាដើម ។*

*បានឮថា ថ្ងៃមួយ ព្រះនាងកើតវិវាទអាស្រ័យនឹងព្រះបន្ទំមួយអន្ទើដោយព្រះរាជា ។ ព្រះរាជាក្រោធហើយ មិនសម្លឹងមើលព្រះនាង ។ ព្រះនាងគិតថា តើព្រះតថាគតទ្រង់ជ្រាបថា ព្រះរាជាក្រោធនឹងយើងឬទេ ។ ព្រះសាស្តាដឹងហេតុនោះ ក្នុងថ្ងៃស្អែក ព្រះអង្គមានភិក្ខុសង្ឃចោមរោម ចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ស្តេចយាងទៅកាន់ទ្វាររាំង របស់*

ព្រះរាជា ។ ព្រះរាជាក្រោកទៅទទួលបាត្រ និមន្តព្រះសាស្តាឡើងកាន់ប្រាសាទ ឲ្យព្រះភិក្ខុសង្ឃគង់តាមលំដាប់ ថ្វាយទក្ខិណោទក[1] អង្គាសដោយបណីតាហារ ក្នុងវេលាធ្វើភត្តកិច្ចស្រេចហើយ ព្រះអង្គគង់លើទីដ៏សមគួរមួយ ។ ព្រះសាស្តាត្រាស់សួរថា បពិត្រមហារាជ ហេតុដូចម្តេច បានជាមិនឃើញព្រះនាងមល្លិកា កាលព្រះរាជាទូលថា ព្រះនាងស្រវឹងនឹងសេចក្តីសុខរបស់ខ្លួន ។ ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ព្រះអង្គក្នុងកាលមុន បានកើតក្នុងកំណើតសត្វកិន្នរ បានព្រាត់ប្រាសកិន្នរីអស់មួយរាត្រី ជាអ្នកបរិទេវៈ ប្រព្រឹត្តទៅអស់ ៧០០ ឆ្នាំ មិនមែនឬ កាលព្រះរាជាទូលអារាធនាហើយ ព្រះអង្គទើបនាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះរាជា ព្រះនាម **ភល្លាតិយៈ** សោយរាជសម្បត្តិ ក្នុងនគរពារាណសី ។ ព្រះរាជានោះត្រិះរិះថា យើងនឹងបរិភោគសាច់ម្រឹគអាំង ទើបប្រគល់រាជ្យដល់ពួកអាមាត្យ ទ្រង់កាន់យកបញ្ចាវុធដែលចងព្រមហើយ មានពួកកោលេយ្យសុខនដែលហ្វឹកហាត់ល្អ ចោមរោមហើយ ស្តេចចេញចាកព្រះនគរ ចូលកាន់ហិមវន្ត យាងដល់ទន្លេគង្គាតូច កាលមិនអាចនឹងឡើងខាងលើ ទ្រង់ឃើញស្ទឹងមួយដែលហូរឆ្លងកាត់ទន្លេគង្គា ទើបយាងទៅតាមក្រសែទឹកនោះ ហើយសម្លាប់ម្រឹគនិងជ្រូកជាដើម សោយសាច់ដែលឆ្អិនដោយរងើកភ្លើង រួចស្តេចឡើងកាន់ទីខ្ពស់ ។ ក្នុងទីនោះ មានស្ទឹងគួរជាទីរីករាយ ក្នុងវេលាដែលមានទឹកពេញ មានជម្រៅប្រមាណត្រឹមដោះហូរទៅ ក្នុងពេលដទៃ ទឹកនោះមានប្រមាណត្រឹមជង្គង់។ ក្នុងស្ទឹងនោះ មានត្រី និងអណ្តើកច្រើនប្រការត្រាច់ទៅ ។ ក្នុងទីបំផុតនៃទឹកមានខ្សាច់ពណ៌ដូចផ្ទាំងប្រាក់ លើច្រាំងទាំងពីរមានដើមឈើដ៏ដេរដាសដោយផ្កានិងផ្លែផ្សេងៗ មានពួកបក្សី

---

១. ទឹកជាគ្រឿងចម្រើន គឺទឹកដែលច្រួចដាក់លើបាតដៃនៃបដិគ្គាហកបុគ្គល ក្នុងពេលដែលគេឲ្យទានរួចភ្លាមៗ : នៅពេលវេរឱ្យបោសថាគារថ្មី ទាយកបានច្រួចទក្ខិណោទកលើហត្ថា នៃលោកចៅអធិការ។ អ្នកខ្លះហៅទក្ខិណោទក នេះថា ទក្ខោទក អ្នកខ្លះថា ទឹកស្នោទក (--ទក់) ដោយហៅក្លាយពីសំស្ក្រឹតថា ទក្សិណោទក ។

និងកមរជាតិមានប្រការផ្សេងៗ ដែលស្រវឹងក្នុងរសផ្កានិងផ្លែនាំគ្នាមកក្រេបផឹក ហើយមានពួកម្រឹគប្រការផ្សេងៗ មកអាស្រ័យនឹងម្ប់ដ៏ត្រជាក់ ។ នៅនឹងច្រាំងហេមវតនទី ដែលជាទីគួររីករាយនេះ មានកិន្នរនិងកិន្នរី ២ ឱបរឹត ហើយបឺតជញ្ជក់នូវគ្នានឹងគ្នា យំខ្សឹកខ្សួលរៀបរាប់ដោយប្រការផ្សេងៗ ។

ព្រះរាជាកាលឡើងភ្នំគន្ធមាទន៍ ដែលនៅខាងច្រាំងទន្លេនោះ ក៏បានឃើញកិន្នរទាំងនោះហើយគិតថា ហេតុដូចម្តេចបានជាកិន្នរទាំងនោះយំ យើងនឹងសួរគេមើល៍ ដូច្នេះទើបទ្រង់សម្ងំមើលសុនខ ហើយផ្ទាត់ម្រាមដៃ ។ កោលេយ្យសុនខទាំងឡាយដែលហ្វឹកហាត់ល្អហើយក៏ចូលទៅកាន់គុម្ពឈើដោយសញ្ញានោះ ហើយដេកក្រាបចុះដោយទ្រូង ។ ព្រះរាជាដឹងភាពដែលសុនខទាំងនោះ ពួនសម្ងំស្ងៀមហើយ ក៏ដាក់ធ្នូនិងអាវុធដ៏សេស ឲ្យអាស្រ័យនឹងដើមឈើ ទ្រង់មិនធ្វើឲ្យមានសំឡេងព្រះបាទ យាងទៅកាន់សម្នាក់កិន្នរទាំងនោះយ៉ាងសន្សឹមៗ ហើយសួរកិន្នរទាំងនោះថា ព្រោះហេតុអ្វី បានជាអ្នកទាំងឡាយយំ ។

ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ ៣ ព្រះគាថាថា

**ភល្លាតិយោ នាម អហោសិ រាជា, រដ្ឋំ បហាយ មិគវំ អចារិ សោ;**
**អគមា គិរិវរំ គន្ធមាទនំ, សុបុប្ផិតំ កិម្បុរិសានុចិណ្ណំ។**

ព្រះរាជាព្រះនាមភល្លាតិយៈ បានលះបង់នូវដែន ហើយត្រេចចេញទៅកាន់ទីសម្លាប់ម្រឹគ ព្រះអង្គបានយាងទៅដល់ភ្នំ ដ៏ប្រសើរឈ្មោះគន្ធមាទន៍ មានឈើផ្ការីកស្គុះស្គាយ ដ៏ដេរដាសដោយពួកកិន្នរ ។

**សាឡូរសង្ឃញ្ច និសេធយិត្វា, ធនុំ កលាបញ្ច សោ និក្ខិបិត្វា;**
**ឧបាគមិ វចនំ វត្តុកាមោ, យត្ថដ្ឋិតា កិម្បុរិសា អហេសុំ។**

*ព្រះអង្គប្រាថ្នាដើម្បីពោលពាក្យ (នឹងពួកកិន្នរ) ទើបហាម ឃាត់ហ្វូងឆ្កែ ហើយដាក់ចុះនូវធ្នូនិងបំពង់ព្រួញ រួចចូលទៅត្រង់កន្លែងដែលពួកកិន្នរឋិតនៅ ។*

**ហិមច្ចយេ ហេមវតាយ តីរេ, កិម្ហិធដ្ឋិតា មន្តយវ្ហោ អភិណ្ហំ;**
**បុច្ឆាមិ វោ មានុសទេហវណ្ណា, កថំ វោ ជានន្តិ មនុស្សលោកេ។**

*(ព្រះរាជាសួរថា) កាលកន្លងហេមន្តរដូវទៅហើយ ម្តេចឡើយ អ្នកទាំងឡាយឋិតនៅក្នុងទីនេះ ប្រឹក្សាគ្នារឿយៗ ប្របឆ្នេរស្ទឹងហេមវតី យើងសូមសួរពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចជាមនុស្ស គេស្គាល់អ្នកទាំងឡាយបាន ក្នុងមនុស្សលោកដោយប្រការដូចម្តេច ។*

*បណ្តាបទទាំងនោះ បទថា* **សាឡូរសង្ឃំ** *បានដល់ ហ្វូងសុនខ ។ បទថា* **ហិមច្ចយេ** *សេចក្តីថា កន្លង ៤ ខែនៃហេមន្តរដូវ ។ បទថា* **ហេមវតាយ** *សេចក្តីថា ប្រាំងស្ទឹងហេមវតីនេះ ។*

*កិន្នរស្តាប់ពាក្យរបស់ព្រះរាជាហើយ ក៏នៅស្ងៀម ចំណែកនាងកិន្នរី ក៏ចរចាជាមួយនឹងព្រះរាជាថា*

**មល្លំ គិរឹ បណ្ឌរកំ តិកូដំ, សីតោទកា អនុវិចរាម នជ្ជោ;**
**មិគា មនុស្សាវ និភាសវណ្ណា, ជានន្តិ នោ កិម្បុរិសាតិ លុទ្ទា។**

*ម្នាលព្រាន ពួកយើងតែងត្រេចទៅកាន់ភ្នំ ឈ្មោះមាលាគិរី ភ្នំឈ្មោះបណ្ឌរកៈ ភ្នំត្រៃកូដនិងស្ទឹងមានទឹកដ៏ត្រជាក់ ពួកយើងជាម្រឹគ មានភេទប្រាកដដូចជាមនុស្ស គេស្គាល់ពួកយើងថាជា កិន្នរ ។*

*លំដាប់នោះ ព្រះរាជាត្រាស់ ៣ គាថាថា*

សុកិច្ចរូបំ បរិទេវយន្តំ, អាលិង្គិតោ ចាសិ បិយោ បិយាយ;
បុច្ឆាមិ វោ មានុសទេហវណ្ណា, កិមិធ វនេ រោទថ អប្បតីតា។

អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ ឱបរឹតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចមនុស្ស អ្នកទាំងឡាយ អាក់អន់ចិត្តដូចម្ដេច ទើបទួញយំក្នុងព្រៃនេះ ។

សុកិច្ចរូបំ បរិទេវយន្តំ, អាលិង្គិតោ ចាសិ បិយោ បិយាយ;
បុច្ឆាមិ វោ មានុសទេហវណ្ណា, កិមិធ វនេ វិលបថ អប្បតីតា។

អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ ឱបរឹតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចជាមនុស្ស អ្នកទាំងឡាយ អាក់អន់ចិត្តដូចម្ដេច ទើបយំរៀបរាប់ក្នុងព្រៃនេះ ។

សុកិច្ចរូបំ បរិទេវយន្តំ, អាលិង្គិតោ ចាសិ បិយោ បិយាយ;
បុច្ឆាមិ វោ មានុសទេហវណ្ណា, កិមិធ វនេ សោចថ អប្បតីតា។

អ្នកទាំងពីរ មានសភាពដូចជាទុកក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ ឱបរឹតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចជាមនុស្ស អ្នកអាក់អន់ចិត្តដូចម្ដេច ទើបសោកស្ដាយក្នុងព្រៃនេះ ។

*បទថា* **សុកិច្ចរូបំ** *សេចក្ដីថា ដូចជាដល់សេចក្ដីទុក្ខខ្លាំង ។ បទថា* **អាលិង្គិតោ ចាសិ បិយោ បិយាយ** *សេចក្ដីថា អ្នកជាទីស្រឡាញ់ ត្រូវកិន្នរីជាទីស្រឡាញ់ឱបរឹត ។ បទ*

*ថា* **គិមិធ វាទេ** *សេចក្ដីថា ព្រោះហេតុអ្វី បានជាអ្នកទាំងពីរឱបរឹត បឹតជញ្ជក់គ្នា ហើយពោលពាក្យជាទីស្រឡាញ់ ជាចន្លោះដល់គ្នានឹងគ្នា យំរៀបរាប់ មិនស្រាកសោះចឹង ។*

*បន្ទាប់ពីនេះទៅ ជាអាលាបសល្លាបគាថា ( គាថាដែលនិយាយគ្នាដោយស្រួល) របស់អ្នកព្រះរាជានិងនាងកិន្នរីនោះ ។*

នាងកិន្នរីពោលថា

មយេករត្តឹ វិប្បវសិម្ហ លុទ្ទ, អកាមកា អញ្ញមញ្ញំ សរន្តា;
តមេករត្តឹ អនុតប្បមានា, សោចាម'សា រត្តិ បុនំ ន ហេស្សតិ។

*ម្នាលព្រាន យើងទាំងឡាយជាអ្នកព្រាតប្រាស់គ្នា អស់មួយរាត្រី រលឹកគ្នាទៅវិញទៅមកមិនដាច់អាល័យ ក្ដៅក្រហាយនឹងរាត្រីមួយនោះ ទើបយំសោក រាត្រីនោះនឹងមិនមានទៀត ។*

ព្រះរាជាត្រាស់ថា

យមេករត្តឹ អនុតប្បថេតំ, ធនំវ នដ្ឋំ បិតរំវ បេតំ;
បុច្ឆាមិ វោ មានុសទេហវណ្ណេ, កថំ វិនា វសមកប្បយិត្ថ។

*អ្នកទាំងឡាយក្ដៅក្រហាយនឹងរាត្រីមួយណា ដូចបុគ្គលក្ដៅក្រហាយនឹងទ្រព្យ ដែលបាត់ និងមាតាបិតាដែលទៅកាន់បរលោក យើងសូមសួរនូវពួកអ្នកដែលមានរាងកាយនិងសម្បុរដូចមនុស្ស ចំពោះរាត្រី ( នោះ) តើអ្នកទាំងឡាយសម្រេចនូវទីនៅផ្សេងគ្នាដូចម្ដេច ។*

នាងកិន្នរីពោលថា

យមិមំ នទឹ បស្សសិ សីឃសោតំ, ណាណាទុមច្ឆាទនំ សេលកូលំ;
តំ មេ បិយោ ឧត្តរិ វស្សកាលេ, មមញ្ច មញ្ញំ អនុពន្ធតីតិ។

អ្នកឃើញនូវស្ទឹងណា ដែលមានខ្សែទឹកដ៏រហ័ស ជាស្ទឹងបិទបាំង ដោយដើមឈើផ្សេងៗ មានមាត់ច្រាំងដ៏ហើយដោយថ្ម កិន្នរ (ជាប្តី) ជាទីស្រឡាញ់របស់ខ្ញុំ បានហែលឆ្លងស្ទឹងនោះ ក្នុងកាលរដូវភ្លៀង ដោយគិតថា កិន្នរីមកតាមក្រោយអាត្មាអញដែរ ។

អហញ្ច អង្កោលកមោចិនាមិ, អតិមុត្តកំ សត្តលិយោថិកញ្ច;
‘បិយោ ច មេ ហេហិតិ មាលភារី, អហញ្ច នំ មាលិនី អជ្ឈុបេស្សំ។

ចំណែកខាងខ្ញុំ កំពុងតែបេះផ្កាព្រូស[១] ផ្កាទន្ទា[២] ផ្កាម្ទិះរូត និងផ្កាយុថ្កា ដោយបំណងថា កិន្នរ (ជាប្តី) ជាទីស្រឡាញ់របស់អាត្មាអញនឹងបានប្រដាប់កម្រងផ្កា ទាំងអាត្មាអញជាអ្នកប្រដាប់កម្រងផ្កា នឹងបានចូលទៅរកកិន្នរ (ជាប្តី) នោះ (ក្នុងដំណេក) ។

អហញ្ចិទំ កុរវកមោចិនាមិ, ឧទ្ទាលកា បាដលិសិន្ទុវារកា;
‘បិយោ ច មេ ហេហិតិ មាលភារី, អហញ្ច នំ មាលិនី អជ្ឈុបេស្សំ។

---

១. ឈ្មោះឈើព្រៃមួយប្រភេទ ពួកទ្រមូងមានផ្លែប្រើជាអាហារបាន : *ផ្លែព្រូស* ។ ២. ឈ្មោះឈើមួយប្រភេទ ពួកថ្វាន់ ច្រើនដុះតែនៅព្រៃរនាម ឬនៅមាត់បឹង, ស្ទឹង, ព្រែក...។ ៣. ឈ្មោះឈើមួយប្រភេទ មានស្លឹកវែងៗ ស្រួចៗ ជាឈើធំ មានផ្កាចេញទងពីតួដើម និងពីមែកធំៗ ផ្កាមូលៗធំៗ (មានសណ្ឋានស្រដៀងនឹងនាគម៉ុងសាយចិន) សម្បុរក្រហមលាយលឿង មានក្លិនក្រអូបឈ្ងប់ រីកហើយធាប់ពោយទៅវិញ ជ្រុះត្របកនិងកេសរមកពោយរាយលើផែនដី ផ្លែមូលៗធំៗជាងផ្លែក្រឡៅ ក្នុងមួយឆ្នាំៗជ្រុះស្លឹកអស់រលីងច្រើនដងហើយលាស់ត្រួយខ្ចីភ្លាមៗ មិនបង្អង់យូរ ។ល។ ព្រះសិទ្ធត្ថសក្យមុនីគោតម ទ្រង់ប្រសូតទាំងទ្រង់បរិនិព្វានផងដែរនៅក្រោមដើមសាលព្រឹក្សនេះ (ខ្មែរធ្លាប់យល់មកថា ដើមរាំងភ្នំ ផ្ទុយពីការពិត)។ ឈើនេះមានឈ្មោះហៅបានបីយ៉ាងគឺហៅថា សាលព្រឹក្ស *ក៏បាន, ហៅ*អស្សកណ្ណព្រឹក្ស *ក៏បាន, ហៅ*សជ្ជព្រឹក្ស ក៏បាន ។ កាលពីក្នុងបុរាណសម័យ ឈើនេះមានតែឯប្រទេសឥណ្ឌា, សព្វថ្ងៃនេះមានសម្បូរណ៍ក្នុងប្រទេសកម្ពុជា ច្រើនតែក្នុងវត្តអារាមនៃភិក្ខុសង្ឃ, ជាឈើមានគ្រាប់ងាយបណ្តុះងាយដាំតាមតែដីបែបណាក៏ដាំបានដែរ ។

មួយទៀត ខ្ញុំបេះផ្កាកុរវកៈ ទាំងផ្កាពជព្រឹក និងផ្កាប្រទៀនក៏ខ្ញុំបេះ ដោយបំណងថា កិន្នរ (ជាប្តី) ជាទីស្រឡាញ់របស់អាត្មាអញនឹងជាអ្នកប្រដាប់កម្រងផ្កា ទាំងអាត្មាអញក៏ជាអ្នកប្រដាប់កម្រងផ្កា នឹងបានចូលទៅរកកិន្នរ (ជាប្តី) នោះ (ក្នុងដំណេក) ។

អហញ្ច សាលស្ស សុបុប្ផិតស្ស, ឱចេយ្យ បុប្ផានិ ករោមិ មាលំ;
'បិយោ ច មេ ហោហិតិ មាលការី, អហញ្ច នំ មាលិនី អជ្ឈុបេស្សំ។

មួយទៀត ខ្ញុំបានបេះនូវផ្កាសាលព្រឹក[៣] ដែលរីកស្គុះស្គាយ ធ្វើជាគ្រឿងប្រដាប់ដោយបំណងថា កិន្នរ (ជាប្តី) ជាទីស្រឡាញ់របស់អាត្មាអញនឹងជាអ្នកប្រដាប់កម្រងផ្កា ទាំងអាត្មាអញក៏ជាអ្នកប្រដាប់កម្រងផ្កា នឹងបានចូលទៅរកកិន្នរ (ជាប្តី) នោះ (ក្នុងដំណេក)[៤] ។

អហញ្ច សាលស្ស សុបុប្ផិតស្ស, ឱចេយ្យ បុប្ផានិ ករោមិ ភារំ;
ឥទញ្ច នោ ហោហិតិ សន្ថរត្ថំ, យត្ថជ្ជិមំ វិហរិស្សាម រត្តឹ។

មួយទៀត ខ្ញុំបានបេះនូវផ្កាសាលព្រឹក ដែលរីកស្គុះស្គាយ ធ្វើជាគ្រឿងប្រដាប់ដោយបំណងថា ថ្ងៃនេះយើងនឹងនៅក្នុងទីណា អស់រាត្រីមួយ គ្រឿងប្រដាប់នេះ នឹងបានជាកម្រាលរបស់យើងក្នុងទីនោះ ។

អហញ្ច ខោ អគឡុំ ចន្ទនញ្ច, សិលាយ បឹសាមិ បមត្តរូបា;
'បិយោ ច មេ ហោហិតិ រោសិតង្គោ, អហញ្ច នំ រោសិតា អជ្ឈុបេស្សំ។

៤. បិដកខ្មែរប្រែបាត់មួយគាថានេះ ។

មួយទៀត ខ្ញុំមានសភាពជាអ្នកធ្វេសប្រហែស ក្លិនខ្លឹមក្រស្នា និងខ្លឹមចន្ទន៍លើថ្ម ដោយបំណងថា កិន្នរជាប្តីជាទីស្រឡាញ់របស់អាត្មាអញ នឹងបានលាបខ្លួនប្រាណ ទាំងខ្លួនអញក៏បានលាបស្រឡាប ហើយនឹងចូលទៅរកកិន្នរជាប្តីនោះក្នុងដំណេក ។

**អថាគមា សលិលំ សីឃសោតំ, នុទំ សាលេ សលឡេ កណ្ណិការេ;**
**អាបូរេថ តេន មុហុត្តកេន, សាយំ នទី អាសិ មយា សុទុត្តរា។**

លំដាប់នោះ ទឹកស្ទឹងមានខ្សែដ៏រហ័ស ហូរគួចយកផ្កាសាលព្រឹក្ស ផ្កាស្រស់និងផ្កាកណ្ណិការ (ដែលខ្ញុំបេះទុក ក្នុងទីទៀបមាត់ច្រាំង) មានទឹកដ៏ពេញដោយមួយរំពេច ទាំងស្ទឹងនោះ ខ្ញុំក៏ឆ្លងបានដោយកម្រដក្រៃលែង ។

ពាក្យថា **ឆ្លងបានដោយកម្រដក្រៃលែង** សេចក្តីថា ក្នុងវេលាដែលនាងកិន្នរីឈរនៅច្រាំងម្ខាងនោះឯង ទឹកក្នុងស្ទឹងក៏ហូរឡើងមក ទាំងក្នុងខណៈដែលព្រះអាទិត្យអស្តង្គតទៅ ក្រសែទឹកហូរត្របាញ់ខ្លាំង តាមធម្មតា សត្វកិន្នរទាំងឡាយជាសត្វខ្លាចទឹក ព្រោះហេតុនោះ នាងកិន្នរីនោះ ទើបមិនអាចឆ្លងទៅច្រាំងម្ខាងទៀតបាន ។

**ឧភោសុ តីរេសុ មយំ តទា ឋិតា, សម្បស្សន្តា ឧភយោ អញ្ញមញ្ញំ;**
**សកិម្បិ រោទាម សកិំ ហសាម, កិច្ឆេន នោ អាគមា សំវរី សា។**

គ្រានោះ យើងទាំងពីរនាក់ក៏ឈរប្រេបឆ្នេរស្ទឹងម្ខាងម្នាក់ មើលឃើញគ្នាទៅវិញទៅមក ម្តងយំ ម្តងសើច រាត្រីនោះ របស់យើងក៏កន្លងទៅដោយក្រ ។

**ចាតោវ ខោ ឧគ្គតេ សូរិយម្ហិ, ចតុក្កំ នទិំ ឧត្តរិយាន លុទ្ទ;**
**អាលិង្គិយា អញ្ញមញ្ញំ មយំ ឧភោ, សកិម្បិ រោទាម សកិំ ហសាម។**

*ម្នាលព្រាន កាលបើព្រះអាទិត្យរះឡើង ក្នុងវេលាព្រឹក យើងទាំងពីរនាក់ក៏ចូលស្ទឹងទទេ (ស្ទឹងមិនមានទឹក) ហើយ ឱបរឹតគ្នាទៅវិញទៅមក ម្តងយំ ម្តងសើច ។*

*ពាក្យថា ម្តងយំ ម្តងសើច សេចក្តីថា ពេលណាងងឹតមើលមិនឃើញគ្នាក៏យំ ពេលភ្លឺមើលឃើញគ្នា ក៏សើច ។*

តីហ្វានតាំ សត្ត សតានិ លុទ្ទ, យមិធ មយំ វិប្បវសិម្ហ បុព្វេ;
វស្សេកិមំ ជីវិតំ ភូមិបាល, កោ ឥធ កណ្តាយ វិនា វសេយ្យ។

*ម្នាលព្រាន កាលមុន យើងបានព្រាត់ប្រាស់គ្នាអស់មួយរាត្រី កន្លងមកចំនួន ៧០០ ខ្វះ ៣ ឆ្នាំ (៦៩៧) ម្នាលភូមិបាល ជីវិត (របស់អ្នក) នេះ ត្រឹមតែមួយរយឆ្នាំ អ្នកណាហ្ន៎ ក្នុង លោកនេះ នៅផ្សេងគ្នាអំពីភរិយាជាទីស្រឡាញ់អរបាន ។*

ព្រះរាជាត្រាស់ថា

អាយុញ្ច វោ កីវតកោ នុ សម្ម, សចេបិ ជានាថ វទេថ អាយុំ;
អនុស្សវា វុឌ្ឍតោ អាគមា វា, អក្ខាថ មេតំ អវិកម្បមានា។

*នៃសម្លាញ់ ចុះអាយុរបស់អ្នកទាំងឡាយ ចំនួនប៉ុន្មាន បើអ្នកដឹង ចូរអ្នកប្រាប់អាយុ (ដល់យើង) ទោះបីអ្នកបានឮ (អំពីអ្នកណាមួយ) ក្តី ចាំតមកអំពីពួកជនចាស់ទុំក្តី សូមអ្នកកុំញញើតប្រាប់សេចក្តីនោះ ដល់យើង ។*

ជាងកិន្នរីពោលថា

អាយុញ្ច នោ វស្សសហស្សំ លុទ្ទ, ន ចន្តរា ចាបកោ អត្ថិ រោគោ;
អប្បញ្ច ទុក្ខំ សុខមេវ ភិយ្យោ, អវីតរាគា វិជហាម ជីវិតំ។

***ម្នាលព្រាន អាយុរបស់យើងមួយពាន់ឆ្នាំ បើមិនមានរោគដ៏អាក្រក់ ក្នុងចន្លោះអាយុទេ ឯសេចក្តីទុក្ខមានប្រមាណតិច សេចក្តីសុខហ្នឹងឯង មានច្រើនក្រៃលែង ពួកយើងមិនប្រាស ចាកសេចក្តីត្រេកអរ (ស្រឡាញ់គ្នា) ទាល់តែលះជីវិតទៅ។***

*ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់គិតថា សត្វតិរច្ឆានទាំងឡាយនេះព្រាត់ប្រាសគ្នា អស់មួយរាត្រីប៉ុណ្ណោះ យំសោយសោករហូតអស់ ៧០០ ឆ្នាំត្រាច់ទៅ ចំណែកយើងលះបង់ រាជសម្បត្តិដ៏ធំដែលមានប្រមាណ ៣០០ យោជន៍ មកត្រាច់ទៅក្នុងព្រៃ ឱហ្ន៎ យើងធ្វើកិច្ច ដែលមិនគួរសោះ ដូច្នេះហើយ ទ្រង់ក៏បានត្រឡប់អំពីនោះ យាងទៅនគរពារាណសី ព្រះអង្គ ដែលពួកអាមាត្យទូលសួរថា បពិត្រមហារាជ ព្រះអង្គទតឃើញអ្វី ជាវត្ថុដ៏អស្ចារ្យក្នុងព្រៃ ហិមពាន្ត ? ទ្រង់ក៏ប្រាប់រឿងរ៉ាវទាំងអស់ ចាប់តាំងអំពីនោះមក ទ្រង់បានឲ្យទាន ហើយ សោយភោគសម្បត្តិ តរៀងទៅ។*

*ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ថា*

**ឥទញ្ច សុត្វាន អមានុសានំ, កល្លាតិយោ ឥត្តរំ ជីវិតន្តិ;**
**និវត្តថ ន មិគវំ អចរិ, អទាសិ ទានានិ អភុញ្ជិ ភោគេ។**

***ព្រះរាជាព្រះនាមកល្លាតិយៈ លុះទ្រង់ព្រះសណ្តាប់ពាក្យរបស់ពួកកិន្នរនេះហើយ ក៏ វិលត្រឡប់មក (ព្រះរាជនិវេសន៍) ដោយរំពឹងឃើញថា ជីវិតនេះ មានប្រមាណតិចណាស់ រួច ឈប់ត្រេចទៅ កាន់ទីជាទីសម្លាប់ម្រឹគទៀត ទ្រង់បានបរិច្ចាគទាន ទ្រង់បានប្រើប្រាស់នូវ ភោគ សម្បត្តិ (តាមធម្មតា)។***

*ព្រះសាស្តាត្រាស់គាថានេះហើយ កាលនឹងឲ្យឱវាទបន្ថែមទៀត ទើបត្រាស់ ២ ព្រះ គាថាថា*

ឥទញ្ច សុត្វាន អមានុសានំ, សម្មោទថ មា កលហំ អកត្ថ;
មា វោ តបី អត្តកម្មាបរាធោ, យថាបិ តេ កិម្បុរិសេករត្តិំ។

*សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកកិន្នរនេះហើយ ចូររួសរាយ កុំធ្វើនូវជម្លោះឡើយ កំហុសនៃអំពើរបស់ខ្លួន កុំដុតកម្តៅនូវព្រះអង្គ ដូចជារាត្រីមួយ របស់ពួកកិន្នរ ដុតកម្តៅនូវកិន្នរទាំងនោះ ។*

ឥទញ្ច សុត្វាន អមានុសានំ, សម្មោទថ មា វិវាទំ អកត្ថ;
មា វោ តបី អត្តកម្មាបរាធោ, យថាបិ តេ កិម្បុរិសេករត្តិំ។

*សូមព្រះអង្គ ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកកិន្នរនេះហើយ ចូររួសរាយ កុំធ្វើនូវការវិវាទឡើយ កំហុសនៃអំពើរបស់ខ្លួន កុំដុតកម្តៅនូវព្រះអង្គ ដូចជារាត្រីមួយរបស់ពួកកិន្នរ ដុតកម្តៅនូវកិន្នរទាំងនោះ ។*

*ព្រះនាងមល្លិកាទេវីស្តាប់ព្រះធម្មទេសនារបស់ព្រះតថាគតហើយ ក្រោកចាកអាសនៈ ផ្គងអញ្ជលី កាលនឹងសរសើរព្រះទសពល ទើបត្រាស់ឱសានគាថាថា*

វីជំ អជិមជា សុណោមហំ, វចនបថំ តវ អត្ថសំហិតំ;
មុញ្ចំ គិរំ នុទសេវ មេ ទរំ, សមណា សុខាវហា ជីវ មេ ចិរំ។

*ខ្ញុំម្ចាស់មានចិត្តត្រេកអរ ស្តាប់ធម្មទេសនាមានហេតុផ្សេងៗ គន្លងនៃព្រះបន្ទូលរបស់ព្រះអង្គប្រកបដោយប្រយោជន៍ ព្រះអង្គបញ្ចេញវាចាបន្ទោបង់សេចក្តីក្រវល់ក្រវាយ របស់ខ្ញុំម្ចាស់ បពិត្រព្រះសមណៈ ព្រះអង្គអ្នកនាំសេចក្តីសុខមកឲ្យ សូមព្រះអង្គ គង់ព្រះជន្មនៅអស់កាលយូរ ។*

*ពាក្យថា* ***បពិត្រព្រះសមណៈ ព្រះអង្គអ្នកនាំសេចក្តីសុខមកឲ្យ សូមព្រះអង្គ គង់ព្រះជន្ម នៅអស់កាលយូរ*** *សេចក្តីថា បពិត្រព្រះពុទ្ធសមណៈដ៏ចម្រើន ព្រះអង្គជាអ្នកនាំនូវទិព្វ-មានុសលោកិយសុខ និងលោកុត្តរសុខមកឲ្យដល់ខ្ញុំ បពិត្រព្រះធម្មរាជជាម្ចាស់ សូមព្រះអង្គមានព្រះជន្មគង់នៅអស់កាលយូរ ។*

*ចាប់តាំងអំពីពេលនោះមក ព្រះបាទកោសលក៏នៅដោយសមគ្គវាស (ការនៅរួមគ្នា) មួយអន្លើដោយព្រះនាងមល្លិកានោះវិញ ។*

*ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា*

**តទា កិន្នរោ កោសលរាជា អហោសិ** *កិន្នរក្នុងកាលនោះ បានមកជាព្រះបាទកោសល*

**កិន្នរី មល្លិកា ទេវី** *នាងកិន្នរីបានមកជាព្រះនាងមល្លិកា*

**ភល្លាតិយរាជា អហមេវ អហោសិំ** *ចំណែកព្រះបាទភល្លាតិយៈ គឺតថាគតនេះឯង ។*

*ចប់ ភល្លាតិយជាតក ៕*

*(ជាតដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក វីសតិនិបាត បិដកលេខ ៦០ ទំព័រ ១០២)*

*ថ្ងៃព្រហស្បតិ៍ ៣ កើត ខែជេស្ឋ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ១៧ ខែ ឧសភា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*